

HBS LAW
ក្រុមហ៊ុនមេធាវី អេច ប៊ី អេស

# អាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់

May 2021 Publication

**“Local expertise with international experience makes us the advisor of choice”**

ច្បាប់សំណង់ថ្មីឆ្នាំ ២០១៩ តម្រូវឲ្យមានការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់ជាប្រចាំដើម្បីធានាឲ្យបាននូវគុណភាព និងសុវត្ថិភាព មុនពេលប្រើប្រាស់ ឬដាក់សំណង់នោះឲ្យប្រើប្រាស់ ។ បុគ្គលដែលមានបំណងអនុវត្តការត្រួតពិនិត្យ និង បញ្ជាក់សំណង់ ត្រូវមានអាជ្ញាបណ្ណចេញដោយក្រសួងដែនដី នគរូបនីយកម្ម និង សំណង់។

បន្ថែមលើ ច្បាប់សំណង់ថ្មីឆ្នាំ ២០១៩ រាជរដ្ឋាភិបាលកម្ពុជា បានចេញអនុក្រឹត្យលេខ ២២៥ អនក្រ.បក នៅថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០២០ ដើម្បីកំណត់អំពី លក្ខខណ្ឌ និងនីតិវិធីនៃការត្រួតពិនិត្យ និងបញ្ជាក់សំណង់ ។ យោងតាមអនុក្រឹតនេះ សំណង់ និងការងារសំណង់ដែលតម្រូវឱ្យមានការត្រួតពិនិត្យ និងបញ្ជាក់សំណង់រួមមាន:

**១.** គម្រោងប្លង់ប្រើប្រាស់សម្រាប់ការងារសាងសង់ ឬរុះរើ មុនអាជ្ញាធរមានសមត្ថកិច្ច ឬមន្ត្រីមានសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតពាក់ព័ន្ធ។

**២.** ការងារសាងសង់ ឬ រុះរើដែលតម្រូវឱ្យមានលិខិតអនុញ្ញាត។

**៣.** សំណង់ដែលត្រូវបានសាងសង់ថ្មី ជួសជុល កែប្រែ ឬប្តូរមុខងារប្រើប្រាស់សំណង់ដែលតម្រូវឲ្យមានវិញ្ញាបនបត្រប្រើប្រាស់សំណង់ ។

**៤.** សំណង់ និង បរិក្ខារសំណង់ដែលតម្រូវឱ្យមានការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពជាទៀងទាត់។

**៥.** សំណង់ដែលមានហានិភ័យចំពោះជីវិតមនុស្ស ទ្រព្យសម្បត្តិ ឬការប៉ះពាល់ដល់សន្តិសុខ ឬសណ្តាប់ធ្នាប់សាធារណៈ ។

ការត្រួតពិនិត្យគុណភាព និង សុវត្ថិភាពសំណង់ អាចត្រូវបានធ្វើឡើងដោយអ្នកត្រួតពិនិត្យ និង បញ្ជាក់សំណង់ឯកជនដែលទទួលបានអាជ្ញាបណ្ណពីក្រសួងដែនដី នគរូបនីយកម្ម និង សំណង់ ។ អាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់មាន ៤ ប្រភេទគឺ អាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ទូទៅ អាជ្ញាបណ្ណត្រួតពិនិត្យ និង បញ្ជាក់សំណង់ផ្នែកស្ថាបត្យកម្ម អាជ្ញាបណ្ណត្រួតពិនិត្យ និង បញ្ជាក់សំណង់ផ្នែងគ្រឿងបង្គុំសំណង់ និង អាជ្ញាបណ្ណត្រួតពិនិត្យ និង បញ្ជាក់សំណង់ផ្នែកមេកានិច អគ្គីសនី និង ទឹក ។ អាជ្ញាបណ្ណត្រួតពិនិត្យ និង បញ្ជាក់សំណង់ប្រភេទនីមួយ ត្រូវបានបែងចែកទៅតាមកម្រិតផ្សេងៗ ដែលកំណត់ពីវិសាលភាពនៃការត្រួតពិនិត្យ និង បញ្ជាក់សំណង់របស់អ្នកកាន់អាជ្ញាបណ្ណ ។

ស្ថាបត្យករ ឬ វិស្វករ និង ក្រុមហ៊ុនសញ្ជាតិខ្មែរ និង បរទេស ដែលបំពេញលក្ខខណ្ឌតម្រូវកំណត់ដោយក្រសួងដែនដី នគរូបនីយកម្ម និង សំណង់ មានសិទ្ធិប្រកបវិជ្ជាជីវៈ ឬ អាជីវកម្មត្រួតពិនិត្យ និងបញ្ជាក់សំណង់ ។ ប៉ុន្តែ អាជ្ញាបណ្ណត្រួតពិនិត្យ និង បញ្ជាក់សំណង់ទូទៅ អាចត្រូវផ្តល់ជូនតែក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្មតែប៉ុណ្ណោះ ។ ចំពោះអាជ្ញាបណ្ណបីផ្សេងៗទៀត អ្នកវិជ្ជាជីវៈជារូបវន្តបុគ្គល អាចស្នើសុំបានតែអាជ្ញាបណ្ណកម្រិតទី ៣ ប៉ុណ្ណោះ ។

អាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ មានសុពលភាពបី (៣) ឆ្នាំ និង អាចបន្តជាថ្មីបានក្នុងរយៈពេល សាមសិប (៣) ថ្ងៃមុនពេលផុតកំណត់ ។ ការស្នើសុំ ឬ បន្តអាជ្ញាបណ្ណត្រួតពិនិត្យ និង បញ្ជាក់សំណង់ ត្រូវពិនិត្យ និងសម្រេចដោយក្រសួងដែនដី នរគរូបនីយកម្ម និង សំណង់ក្នុងរយៈពេលម្ភៃ (២០) ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីពេលចេញបង្កាន់ដៃទទួលពាក្យសុំ ។

អ្នកត្រួតពិនិត្យ និង បញ្ជាក់សំណង់ ដែលធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណត្រឹមត្រូវ អាចត្រូវផ្តន្ទាទោសជាការពិន័យរហូតដល់ ៛៤០.០០០.០០០ និង ការដាក់ពន្ធនាគាររហូតដល់បី (៣) ឆ្នាំ ប្រសិនបើនៅតែប្រព្រឹត្តបទល្មើសដដែលក្នុងរយៈពេលមួយ (១) ឆ្នាំ ។

ប្រសិនបើលោក/លោកស្រី ត្រូវការពត៌មានលម្អិតបន្ថែមពាក់ព័ន្ធនឹងអាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ លោក/លោកស្រីអាចធ្វើការទាក់ទងមកក្រុមការងារវិស័យសំណង់ និងដីធ្លីរបស់ **ក្រុមហ៊ុនមេធាវី អេចប៊ីអេស** តាម រយៈអ៊ីម៉ែល៖ keattech@hbslaw.asia ឬ តាម រយៈទូរស័ព្ទលេខ ០២៣ ២២៤ ៣៣៧ ៕

## AUTHORS' PROFILES




**TAN Keattech**
Partner
Head of Construction and Real Estate
Attorney-at-Law



**KEA Pheara**
Legal Assistant
Practice Group Construction and Real Estate



**Phone : +855 (0) 23 224 337**
**Fax : +855 (0) 23 224 136**
**Website : www.hbslaw.asia**
**Email : info@hbslaw.asia**

**HBS Law**
**SOMA Tower (4th & 5th floors)**
**#2C, St. 120, Phsar Thmey 2 (120202)**
**Khan Daun Penh ,Phnom Penh, Cambodia.**